# ចម្លាក់នាងការៃក្កាល្មមៃយ៉ានៅក្នុងសិល្បៈខ្មែរ

ព្រះឥសូរ ជាទេពធំមួយនៅក្នុងព្រហ្មញ្ញសាសនា ដែលមានព្រះនាមច្រើនណាស់ តែព្រះនាមដែលគេតែងស្គាល់ច្រើនមានដូចជា សិវ មហេស្វរ រុទ្រ ហរ អឃោរ ភៃរវ។ ទ្រង់មានតួនាទីជាអ្នកបង្កើតលោកថ្មី និងបំផ្លាញលោកចាស់[1]។ ព្រះឥសូរមានព្រះនេត្រទីបី មានចំណិតព្រះច័ន្ទលើក្បួងសក់ មានព្រះហស្តពីរ ព្រះហស្តប្រាំបី និងព្រះហស្តដប់។ នៅក្នុងសិល្បៈខ្មែរ ទម្រង់របស់ព្រះឥសូរដែលមានព្រះហស្តដប់ ភាគច្រើនគឺបង្ហាញនៅក្នុងឈុត ព្រះឥសូររាំ (Śiva Nataraja) ។ ជាទូទៅនៅក្នុងឈុតព្រះឥសូររាំ គេច្រើនប្រទះឃើញមាននូវក្រុមតន្ត្រីករ កាន់ឧបករណ៍ភ្លេងលេង និងជូនកាលមានព្រះព្រហ្ម និងព្រះវិស្ណុអង្គុយនៅចុងជើងព្រះអង្គក្នុងកាយវិការ អញ្ជលិ (Anjali) ឬក៏ទះដៃតាមភ្លេង[2]។ ក្រៅអំពីក្រុមតន្ត្រីករ និងអាទិទេពធំៗទាំងពីរ គេក៏បានឃើញរូបនារីស្គមស្គាំង ដើមទ្រូងយារធ្លាក់ អង្គុយនៅចុងជើង សម្លឹងមើលព្រះឥសូររាំ ដែលនាងនោះត្រូវបានគេស្គាល់ថាជានាង ការៃក្កាល្មមៃយ៉ា (Kāraikkāl Ammaiyār)។

ដំណើររឿងរបស់នាងការៃក្កាល្មមៃយ៉ា មានរៀបរាប់នៅក្នុងគម្ពីរ Periya Puranam[3] (ពេលខ្លះហៅថា Tiruttontarpuranam ជាកំណាព្យភាសាតាមិលនិយាយអំពីអ្នកគោរពបូជាដ៏បរិសុទ្ធនៃព្រះឥសូរទាំង៦៣រូប) ដែលសរសេរនៅស.វ.ទី១២ ដោយនាយករដ្ឋមន្ត្រីនៃអាណាចក្រ Chola ក្នុងរាជ្យព្រះបាទ Kulottunga II (១១៣៣-១១៥៦នៃគ.ស.) បានសរសេររៀបរាប់ថានាងការៃក្កាល្មមៃយ៉ា កើតនៅទីក្រុង Karaikkal ជាទីក្រុងកំពង់ផែស្ថិតនៅជិត Nagapattinam រដ្ឋ Tamil Nadu ។ នាងមានឈ្មោះដើមថាពុនិតវតិ (Punitavati) ជាអ្នកគោរពបូជាដល់ព្រះឥសូរតាំងពីកុមារភាពមកម្ល៉េះ។ នាងមានសម្រស់ស្រស់ស្អាត ហើយកំណើតរបស់នាងត្រូវបានគេចាត់ទុកថាជាកំណើតរបស់ ព្រះនាងលក្ស្មី[4] (ព្រះនៃទ្រព្យសម្បត្តិនិងរុងរឿង)។ នាងបានរៀបការជាមួយឈ្មួញមានទ្រព្យស្តុកស្តម្ភម្នាក់ឈ្មោះ Paramadatta។ ថ្ងៃមួយស្វាមីរបស់នាងបានផ្ញើផ្លែស្វាយចំនួន២ផ្លែមកផ្ទះរបស់គាត់ដើម្បីឲ្យប្រពន្ធរៀបចំជាអាហារថ្ងៃត្រង់ដល់គាត់។ ពេលនោះមានអ្នកគោរពបូជាម្នាក់របស់ព្រះឥសូរ បានលេចឡើងនៅចំពោះមុខនាង ដោយគាត់មានសេចក្តីស្រេកឃ្លាន និងអស់កម្លាំងជាខ្លាំង។ នាង ពុនិតវតិ (Punitavati) បានឃើញដូច្នេះហើយនោះ ក៏ប្រគល់

(1) Roveda 2005: p.146; Cornelia & Buitenen 1978: 147-216.

(2) Ibid. p.163.

(3) U-tain Wongsathit: 2015, p.2.

(4) Elaine Craddock: 2010, p.74.

អត្ថបទដោយ៖ ងួន ចាន់ដារីយ៉ា

ផ្លែស្វាយចំនួនមួយផ្លែទៅដល់គាត់។ បន្ទាប់មកស្វាមីរបស់នាងបានត្រឡប់មកផ្ទះ នាងបានបម្រើផ្លែស្វាយមួយផ្លែទៀតដល់ស្វាមីរបស់នាង គាត់ប្រាប់ថាគាត់ចូលចិត្តផ្លែស្វាយនោះ និងសុំថែមមួយទៀត។ ពុនិតវតិ (Punitavati) មានភាពភ័យខ្លាចដោយពុំដឹងថាបានផ្លែស្វាយមកពីណាបន្ថែមទៀត ដើម្បីបម្រើដល់ស្វាមី នាងក៏សុំអធិដ្ឋានដល់ព្រះឥសូរឲ្យជួយ ភ្លាមនោះក៏មានផ្លែស្វាយមួយផ្លែធ្លាក់មកលើដៃរបស់នាង។ នាងក៏យកផ្លែស្វាយនោះមកជូនគាត់ ស្វាមីរបស់នាងបានសួរថាតើនាងបានផ្លែស្វាយឆ្ងាញ់នោះមកពីណា នាងក៏រៀបរាប់ដំណើរដើមទងប្រាប់ស្វាមីរបស់នាង។ យ៉ាងណាក៏ដោយ Paramadatta មិនជឿរឿងនេះទេ ហើយបានប្រាប់ឲ្យនាងយកផ្លែស្វាយនោះចេញមកមួយទៀត។ នាងបានអធិស្ឋានដល់ព្រះឥសូរម្តងទៀត ហើយផ្លែស្វាយនោះក៏លេចចេញមក រួចនាងបានប្រគល់វាទៅស្វាមីនាង ប៉ុន្តែភ្លាមៗនោះវាបានបាត់ពីដៃរបស់គាត់[5] ។ ស្វាមីរបស់នាងភ្ញាក់ផ្អើលនិងទទួលស្គាល់នូវភាពអស្ចារ្យរបស់នាង។ គាត់មានអារម្មណ៍ថា វាជាអំពើបាបដ៏ធំមួយក្នុងការរស់នៅជាមួយនាងក្នុងនាមជាប្តីរបស់នាង។ បន្ទាប់មកគាត់បានរត់ចេញពីនាង ដោយធ្វើដំណើរតាមសំពៅ ហើយបានរៀបការជាមួយកូនស្រីឈ្មួញម្នាក់ទៀត។ ពុនិតវតិ (Punitavati) បានដឹងអំពីរឿងនេះហើយក៏ធ្វើដំណើរទៅរកស្វាមីរបស់នាង។ នៅពេល Paramadatta ដឹងថា ពុនិតវតិ (Punitavati) កំពុងមករកទ្រង់ នោះទ្រង់នឹងភរិយានិងកូនទី២ ក៏បានដួលក្រាបទៅនិងជើងរបស់នាងពុនិតវតិ។ នាងពុនិតវតិ បានយល់ពីស្ថានភាពផ្លូវចិត្តរបស់ស្វាមីខ្លួនហើយនោះ នាងក៏បានអធិស្ឋានដល់ព្រះឥសូរ "សុំប្រែរូបរាងរបស់នាងឲ្យទៅជាទម្រង់អារក្ស" [6] រាងកាយដ៏គួរឱ្យទាក់ទាញត្រូវបានផ្លាស់ប្តូរទៅជារូបរាងចំណាស់ និងស្បែកដណ្តប់ឆ្អឹង។ ចាប់តាំងពីពេលនោះមកនាងត្រូវបានគេហៅថា Kāraikkāl Ammaiyār ដែលមានន័យថាម្តាយនៃទីក្រុង Karaikkal [7] ។ បន្ទាប់មកនាងបានធ្វើធម្មយាត្រាទៅកាន់ភ្នំកៃលាស។ នាងមានអារម្មណ៍ថា វាជាអំពើបាបដ៏ធំមួយក្នុងការដាក់ជើងនាងនៅលើកន្លែងពិសិដ្ឋទាំងនោះ។ ដូច្នេះហើយ នាងបានធ្វើដំណើរដោយប្រើដៃទាំងពីររបស់នាង[8] ព្រះនាង បរ័តី មានសេចក្តីភ្ញាក់ផ្អើលពេលឃើញទម្រង់ដ៏ចម្លែក និងការលះបង់ដ៏អស្ចារ្យរបស់នាង។ ព្រះឥសូរបានស្វាគមន៍នាងដោយក្តីស្រឡាញ់ ហើយបានប្រទានពរជ័យដល់នាង។ នាងបានក្រាបនៅជើងរបស់ទ្រង់ ហើយអធិស្ឋានថា "ឱព្រះអម្ចាស់នៃសេចក្តីមេត្តាករុណា សូមប្រទានឱ្យខ្ញុំនូវការលះបង់ដ៏ស្មោះស្ម័គ្រ

(5) U-tain Wongsathit 2015, p.2.

(6) Ibid.

(7) U-tain Wongsathit 2015, p.2.

(8) Ibid.

បរិសុទ្ធ ដល់ទ្រង់ ខ្ញុំមិនចង់កើតទៀតទេ ហើយនៅពេលណាដែលទ្រង់រាំទូលបង្គំត្រូវតែនៅចុងជើងរបស់ទ្រង់ និងច្រៀងសរសើរទ្រង់។ នេះជាបំណងប្រាថ្នាតែមួយគត់របស់ខ្ញុំ[9] ។" ព្រះឥសូរបានប្រទានពរជ័យដល់នាង ហើយបានសុំឱ្យនាងបន្តដំណើរទៅ Tiruvalangadu ដើម្បីធ្វើជាសាក្សីលើការរាំរបស់ទ្រង់ រួចហើយនាងបានទៅកន្លែងនោះ ហើយបានចំណាយមួយជីវិតរបស់នាងច្រៀងសរសើរដល់ព្រះឥសូរ។

នាងការៃក្កាល្អមៃយ៉ា (Kāraikkāl Ammaiyār) កើតនៅទីក្រុង Karaikkal ភាគខាងត្បូងប្រទេសឥណ្ឌា ជាស្ត្រីសំខាន់ម្នាក់ក្នុងចំណោម Nayanmars [10] ទាំង៦៣រូបដែលជាអ្នកគោរពបូជាយ៉ាងស្មោះស្ម័គ្រដល់ព្រះឥសូរ និងប្រហែលជាកវីដំបូងគេដែលសរសេរទំនុកលើកតម្កើងដល់ព្រះឥសូរជាភាសាតាមីល នៅពាក់កណ្តាលសតវត្សទីប្រាំមួយនៃគ.ស.[11]។ ចម្លាក់របស់នាងមានបង្ហាញនៅក្នុងស្រុកខ្មែរ និងស្រុកឥណ្ឌា និងប្រពៃណីសាសនាជាភាសាតាមិឡបុរាណ។ នាងការៃក្កាល្អមៃយ៉ា ត្រូវបានគេស្គាល់យ៉ាងច្រើននាសម័យអាណាចក្រ Chola ដែលរីកចម្រើននៅអំឡុងស.វ.ទី៩រហូតដល់ស.វ.ទី១២។ រូបភាពរបស់នាងនៅក្នុងទម្រង់ជាមនុស្សស្រីវ័យចំណាស់អង្គុយមើលព្រះឥសូររាំ ត្រូវបានរកឃើញនៅតាមជញ្ជាំងប្រាសាទជាច្រើននៅតំបន់ Chola និងនៅទីក្រុង Karaikkal។ មិនតែប៉ុណ្ណោះរូបចម្លាក់ធ្វើអំពីសំរិទ្ធរបស់នាងដែលតំណាងឱ្យទេពីនៃតន្ត្រី ក៏ត្រូវបានប្រទះឃើញនៅទូទាំងអាណាចក្រ Chola ផងដែរ[12]។

បើក្រឡេកមើលចម្លាក់នាងការៃក្កាល្អមៃយ៉ាក្នុងសិល្បៈខ្មែរវិញ នាសម័យមុនអង្គរ គេពុំបានប្រទះឃើញចម្លាក់របស់នាង ការៃក្កាល្អមៃយ៉ា នោះទេ ពោលរហូតមកដល់សម័យអង្គរនៅរវាងស.វ.ទី១០ទើបមានការឆ្លាក់រូបនាង នៅលើផ្តែរ និងហោជាងតាមប្រាសាទនានា ដោយភ្ជាប់ជាមួយនិងចម្លាក់ព្រះឥសូររាំ។ នេះជាចំណុចគួរឲ្យចាប់អារម្មណ៍នៃចម្លាក់របស់នាងនៅតាមប្រាសាទបុរាណនៅក្នុងស្រុកខ្មែរ បានបង្ហាញយ៉ាងច្បាស់អំពីការទទួលឥទ្ធិពលរបស់ Chola មកលើអាណាចក្រអង្គរ តាមរយៈលិទ្ធសាសនា និកាយព្រះឥសូរ។

ចម្លាក់របស់នាង ការៃក្កាល្អមៃយ៉ា ត្រូវបានរកឃើញនៅតាមផ្តែរ និងហោជាងតាមប្រាសាទមួយចំនួននៅក្នុងតំបន់អង្គរ ព្រះវិហារ បាត់ដំបង តាកែវ និងប្រាសាទខ្មែរមួយចំនួននៅ

---

(9) Ibid.

(10) ជាពួកកវីស្ត្រីបរិសុទ្ធដែលគោរពបូជាដល់ព្រះឥសូរនៅទីក្រុងTamil Naduភាគខាងត្បូងប្រទេសឥណ្ឌា នៅរវាងស.វ. ទី៣រហូតដល់ស.វ.ទី០៨ នៃគ.ស.។

(11) Elaine Craddock, 2010, p.1.

(12) U-tain Wongsathit 2015, p.1.

អត្ថបទដោយ៖ ង៉ួន ចាន់ដារីយ៉ា

ភាគខាងជើងស្រុកសៀម។ ប្រាសាទដែលមានឆ្លាក់រូបនាង កាក្រៃក្តាល្មមៃយ៉ា អង្គុយនៅចុង ជើងព្រះឥសូររាំ មានដូចជាប្រាសាទបន្ទាយស្រី សង់ក្នុងសង់នៅឆ្នាំ ៩៦៨ ដោយព្រាហ្មណ៍ យជ្ញ វរាហ ឧទ្ទិសដល់ព្រះឥសូរ។ មានហោជាងមួយឆ្លាក់អំពីសាច់រឿងនៃព្រះឥសូររាំមានដៃ១០ មាន តន្ត្រីករកំពុងលេងភ្លេងនៅផ្នែកខាងឆ្វេង និងរូបស្ត្រីចំណាស់ម្នាក់ សុដន់យារធ្លាក់អង្គុយនៅចុង ជើងខាងស្តាំរបស់ព្រះឥសូរ ដែលប្រហែលជារូបរបស់នាងកាក្រៃក្តាល្មមៃយ៉ា (រូបទី១-២) ។ ចំណែក ផ្តែរនៅប្រាសាទបាសែត (ស.វ.ទី១១) មានឆ្លាក់ជារូបព្រះឥសូររាំមានដៃ១០ និងរូបនាងអង្គុយនៅ ចុងជើងខាងឆ្វេងអង្គុយមើលព្រះឥសូររាំផងដែរ (រូបទី៣-២)។ គេក៏បានរកឃើញផ្តែរជាច្រើននៅ ប្រាសាទព្រះធាតុបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដោយក្នុងចំណោមនោះ មានផ្តែរមួយ មានឆ្លាក់រូបព្រះឥសូររាំ និងមានអាទិទេពនៅជុំវិញ ក្នុងនោះដែលក៏មានរូបនាង កាក្រៃក្តាល្មមៃយ៉ា អង្គុយនៅផ្នែកខាងស្តាំជិតព្រះព្រហ្ម។ នៅក្នុងផ្តែរនេះ សក់របស់នាងដូចទៅនិងរូបនៅហោជាង នៃប្រាសាទបន្ទាយស្រី ចំណែកកាយវិការគឺដូចនិងផ្តែរនៅប្រាសាទបាសែត (រូបទី៥)។ ចម្លាក់ព្រះ ឥសូររាំនៅលើហោជាងប្រាសាទភ្នំជីសូរ្យ (សូរ្យវរ្ម័នទី១ ១០១០-១០៥០នៃគ.ស.) មានឆ្លាក់រូបនាង កាក្រៃក្តាល្មមៃយ៉ា មានលក្ខណៈប្លែកជារូបចម្លាក់ដទៃទៀត ដោយសក់មូលដូចគូទខ្យង ដើមទ្រូង យារធ្លាក់ អង្គុយនៅចុងជើងខាងស្តាំរបស់ព្រះឥសូរ (រូបទី៦)។ ចម្លាក់របស់នាងកក្រៃក្តាល្មម៉ៃ ក៏ត្រូវ បានឆ្លាក់នៅលើហោជាងនៅប្រាសាទព្រះវិហារ (សូរ្យវរ្ម័នទី២ ១១១៣-១១៤៥នៃគ.ស.) ផងដែរ ដោយឆ្លាក់រូបនាងកាក្រៃក្តាល្មមៃយ៉ា មានរូបរាងស្គមស្គាំង អង្គុយនៅចុងជើងខាងស្តាំព្រះឥសូររាំ (រូបទី៧)។ ក្រៅអំពីប្រាសាទនៅក្នុងស្រុកខ្មែរ មានប្រាសាទខ្មែរចំនួន២ទៀតភាគខាងជើងនៃស្រុក សៀម ដែលមានឆ្លាក់រូបនាង កាក្រៃក្តាល្មមៃយ៉ា ។ ប្រាសាទភ្នំរុង ជាប្រាសាទឧទ្ទិសដល់ព្រះឥសូរ ស្ថិតនៅខេត្តបុរីរាម ស្រុកសៀម។ ហោជាងមួយនៃប្រាសាទ ឆ្លាក់រូបព្រះឥសូរមានដៃ១០ ក្នុងកាយ វិការរាំ នៅលើហោជាងនេះ មានរូបស្ត្រី២នាក់ មានរូបរាងស្គម និងមានដើមទ្រូងយារធ្លាក់។ តាម រយៈរូបនេះ គេគិតថា ម្នាក់ជាព្រះនាងឧមាក្នុងទម្រង់ជា ព្រះនាង Chanmudi និងម្នាក់ទៀតជា នាងកាក្រៃក្តាល្មមៃយ៉ា (រូបទី៨)។ មួយទៀតគឺហោជាងនៃប្រាសាទភីម៉ាយ ក្នុងខេត្តនគររាជសីមា ឆ្លាក់រូបព្រះឥសូររាំ និងមានមនុស្សនៅអង្គុយហែរហមសងខាង និងនៅខាងចុងផ្នែកខាងស្តាំមាន រូបស្ត្រីមានរូបរាងស្គមស្គាំង ដើមទ្រូងយារធ្លាក់ ដែលជារូបនាង កាក្រៃក្តាល្មមៃយ៉ា អង្គុយមើលព្រះ ឥសូរសម្តែងបដិហារ (រូបទី៩) ។

ជារួមមក យើងសង្កេតឃើញថារូបចម្លាក់របស់នាងកាក្រៃក្តាល្មមៃយ៉ា លេចឡើងក្នុង សិល្បៈខ្មែរ មាន៣រចនាបថ គឺ រចនាបថបន្ទាយស្រី រចនាបថបាពួន និងរចនាបថអង្គរវត្ត។ នៅ

តាមប្រាសាទបុរាណខ្មែរ គេឆ្លាក់រូបនាងការៃក្កាលម្មៃយ៉ា ក្រោមទម្រង់ជាស្ត្រីដែលមានវ័យចំណាស់ រាងកាយស្គមស្គាំង និងដើមទ្រូងយារធ្លាក់ ហើយចម្លាក់របស់នាងមិនត្រូវបានបង្ហាញឡើងជាចម្លាក់ទោលនោះឡើយ ពោលគឺភាគច្រើនឆ្លាក់រួមជាមួយនិងអាទិទេពផ្សេងៗ និងខ្លះទៀតឆ្លាក់រួមជាមួយនិងក្រុមតន្ត្រីករផ្សេងនៅក្នុងឈុតព្រះឥសូររាំ (Śiva Nataraja)។

## ឯកសារយោង


**Elaine Craddock**

2010, *Śiva's demon devotee Kāraikkāl Ammaiyār*, State University of New York

**Roveda, Victorio**

2005, "*Image of the gods*", Bangkok..

**U-tain Wongsathit**

2015, *Karaikkal Ammaiyar of Chola Country in Ancient Cambodia*, Department of Oriental Languages Silpakorn University, Thailand


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ង៉ួន ចាន់ដារីយ៉ា





រូបទី១-២៖ រូប Kāraikkāl Ammaiyār នៅលើហោជាងប្រាសាទ





រូបទី៣-៤៖ រូប Kāraikkāl Ammaiyār នៅលើផ្ដែរប្រាសាទបាសែត

(ប្រភពរូប៖ ទួន នរិទ្ធ)



រូបទី៥៖រូប Kāraikkāl Ammaiyār នៅលើផ្ដែរប្រាសាទព្រះធាតុបាពយណ៍ (ប្រភពរូប ៖ U-tain Wongsathit)



រូបទី៦៖រូប Kāraikkāl Ammaiyār នៅលើហោជាងប្រាសាទភ្នំជីសូរ (ប្រភពរូប ៖ U-tain Wongsathit)

អត្ថបទដោយ៖ ផ្លូន ចាន់ដារីយ៉ា



រូបទី៧៖រូប Kāraikkāl Ammaiyār នៅលើហោជាង ប្រាសាទព្រះវិហារ (ប្រភពរូប ៖ glorioustamils)



រូបទី៨៖រូប Kāraikkāl Ammaiyār នៅលើហោជាង ប្រាសាទភ្នំរុង (ប្រភពរូប ៖ glorioustamils)



រូបទី៩ ៖រូប Kāraikkāl Ammaiyār នៅលើហោជាង ប្រាសាទភីម៉ាយ

(ប្រភពរូប ៖ glorioustamils)

អត្ថបទដោយ៖ ផួន ចាន់ដារីយ៉ា